**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃពុធ ទី ០៥ ខែសីហា ឆ្នាំ ២០២០

ទំនាក់ទំនង៖ Monique De La Garza
ទូរស័ព្ទ៖ 562-570-6101
អ៊ីម៉ែល ៖ CityClerk@longbeach.gov

# ការិយាល័យរដ្ឋបាលរបស់សាលាក្រុងប្រកាសផ្តល់សេវាកម្មបកប្រែនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់

ចាប់ពីពេលនេះតទៅ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ នឹងមានផ្តល់ជូនការបកប្រែផ្ទាល់ភ្លាមៗនៅពេលមានការស្នើសុំ ដើម្បីឲ្យស្របទៅនឹងគោលការណ៍ផ្តល់សេវាបកប្រែដល់សាធារណជន។ នាពេលអនាគត ដើម្បីធ្វើការស្នើសុំឲ្យមានអ្នកបកប្រែនៅក្នុងកិច្ចប្រជុំ សាធារណជនអាចទាក់ទងទៅការិយាល័យរដ្ឋបាលរបស់សាលាក្រុង ក្នុងរយៈពេល ២៤ ម៉ោង មុនកិច្ចប្រជុំ។

ចាប់តាំងពីថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២០មក នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសង្កាត់ សាលាក្រុងបានអនុញ្ញាតឲ្យសាធារណជនទូរស័ព្ទទៅចូលរួមបញ្ចេញមតិទៅលើរបៀបវារៈនៃអង្គប្រជុំ ។ នេះជាមធ្យោបាយមួយក្នុងការផ្តល់ឱកាសឲ្យពលរដ្ឋបានចូលរួម ខណៈពេលកំពុងគោរពតាមបទបញ្ជា និងការណែនាំផ្នែកសុខាភិបាល ទាក់ទងនឹងមេរោគ COVID-19 ដែលធ្វើឲ្យផ្លាស់ប្តូរទម្លាប់នៃការជួបជុំ និងកិច្ចប្រជុំជាសាធារណៈ។

ការកំណត់ពេលចំនួន 5 នាទី នឹងចាប់អនុវត្តឡើងវិញចំពោះការបញ្ចេញមតិរបស់ចៅសង្កាត់ ហើយក៏នឹងអនុញ្ញាតឲ្យចៅសង្កាត់អាចនិយាយបន្តតាមវេនរបស់ខ្លួនដោយមិនមានកំណត់។ សាលាក្រុងក៏កំពុងធ្វើការសាកល្បងកិច្ចប្រជុំតាមវីដេអូរបស់ចៅសង្កាត់ និងបុគ្គលិក ដែលយើងសង្ឃឹមថានឹងអាចរួមបញ្ចូលគ្នាបានក្នុងពេលដ៏ខ្លីខាងមុខ។

សូមចូលទៅគេហទំព័ររបស់ការិយាល័យរដ្ឋបាលរបស់សាលាក្រុង www.longbeach.gov/cityclerk ដើម្បីស្វែងយល់បន្ថែមអំពីដំណើរការនេះ។

**អំពីទីក្រុង ងប ិ ច**

ទីក្រុង ងប ិ ច មានប្រជាជនប្រមាណ 470,000 រូប ើ យជាទីក្រុងដែលបានទទួលចំណាត់ថ្នាក់ និងជាទីក្រុងដែលមាននវានុវត្តភាព។ ទីក្រុង ងប ិ ចមានផ្តល់ជូននូវភាពជាទីគាប់ចិត្តលំដាប់អន្តរជាតិ បើប្រៀបទៅនឹងប្រភេទទីក្រុងធំៗ ដោយរក្សានូវភាពជាបុគ្គល និងភាពចម្រុះជាតិសាសន៍ ក្នុងការរស់នៅជុំគ្នា តា ឆ្នេរសមុទ្រ កាលីហ្វ័រញ៉ា។ ទីក្រុង ងប ិ ចជាទីក្រុងដែលមានរចនាសម្ព័ន្ធគ្រប់គ្រងមូលដ្ឋានផ្ទាល់ខ្លួនយ៉ាងពេញលេញ ជាទីសំចតនៃនាវា Queen Mary សួនសត្វសមុទ្រ Aquarium of the Pacific សារមន្ទីរ និងសាល ហោស្រពមួយចំនួន អាជ្ញាធរសិក្សាធិការដែលមានគុណភាពខ្ពស់ អាកាសយានដ្ឋាន ងប ិ ច និងកំពង់ផែ ងប ិ ច។ ទីក្រុង ងប ិ ចក៏មាន ហាវិទ្យាល័យ និងសកលវិទ្យាល័យ ដែលទទួលបានការគោរពកោតសរសើរ កសិដ្ឋានជាប្រវត្តិសាស្រ្តចំនួន ២ មន្ទីរពេទ្យចំនួន ៥ ទីលានវាយកូនគោលចំនួន ៥ សួនឧទ្យានចំនួន ១៧១ ឆ្នេរសមុទ្រ កំពង់ផែកំសាន្ត និងផ្លូវទោចក្រយាន្ត ដ៏វែងផងដែរ។

សម្រាប់ព័ត៌មានបន្ថែម អំពីទីក្រុង ងប ិ ច សូ ចូលទៅគេ ទំព័រ http://longbeach.gov/ ។ ើ យសម្រាប់ព័ត៌មានថ្មីៗទាន់ តុការណ៍សូ តា យើ ងខ្ញុំលើបណ្តាញទំនាក់ទំនងសង្គ តា រយៈ ៖ Facebook Twitter Instagram និង YouTube។

###